PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*****

លេខ:០២៨/២១-PPSEZ

# សេចក្ដីជូនដំណឹង
# ស្ដីពី
# ការលាលែងពីតំណែង និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលថ្មី
# របស់ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី** មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និង សាធារណជនមេត្តាជ្រាបថា៖ នៅក្នុងអំឡុងពេលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុនដែល បានប្រារព្ធឡើងនៅថ្ងៃទី ១៧ ខែឧសភាឆ្នាំ ២០២១ ត្រូវបានអនុម័តពីការ លាលែងពីតំណែង និង ជ្រើសរើស ក្រុមប្រឹក្សាភិបាលថ្មី ដោយម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន។

លោក ហែម សុវត្ថិ បានសម្រេចចិត្តលាឈប់ពីតួនាទីជាអភិបាលឯករាជ្យ និង ជាប្រធាន គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងសុំលាលែងពីក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ពីព្រោះអាជីវ កម្មផ្ទាល់ខ្លួនរបស់គាត់តម្រូវឱ្យមានការយកចិត្តទុកដាក់និងពេលវេលាបន្ថែមទៀតដើម្បីគ្រប់គ្រងក្នុងប្រតិបត្តិ ការ និងការគ្រប់គ្រងនាពេលថ្មីៗនេះ។ នេះជាការពន្យល់របស់គាត់ដែលផ្ដល់ឱ្យក្រុមប្រឹក្សាភិបាលទាក់ទង នឹងហេតុផលរបស់គាត់ក្នុងការលាលែង។

ដោយអវត្តមានរបស់លោក ហែម សុវត្ថិ PPSP បានបោះឆ្នោតជ្រើសរើសលោក ARTHUR LAW HIAN TAT ជាអភិបាលឯករាជ្យ និងជា ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ជាជនជាតិម៉ាឡេស៊ី ជំនាញខាងគណនេយ្យករ។ ក្នុងបទពិសោធន៍លោកជាង ៤០ ឆ្នាំជាគណនេយ្យករ លោក ARTHUR បាន ធ្វើការនៅប្រទេសម៉ាឡេស៊ី អូស្ត្រាលី កម្ពុជា និងឡាវ។ គាត់គឺជាសមាជិកសកម្មរបស់ KICPAA ។ លោក ARTHUR ក៏ធ្លាប់មានសកម្មភាពជាច្រើននៅកម្ពុជាកាលពីដើមឆ្នាំ ២០០០-២០១០ ។

ក្នុងរយៈពេលជិតម្ភៃឆ្នាំនៃការបម្រើការងារនៅប្រទេសកម្ពុជា លោក ARTHUR បានធ្វើការជាមួយ អតិថិជនពីវិស័យជាច្រើនរាប់ចាប់ពីវិស័យអ្នកប្រើប្រាស់រហូតដល់វិស័យសំណង់និងថាមពលក៏ដូចជាការធ្វើ សវនកម្មរបស់អង្គការក្នុងវិស័យសាធារណៈ។ គាត់ក៏ជាដៃគូចូលរួមក្នុងការចុះបញ្ជីក្រុមហ៊ុនឯកជនចំនួនពីរ

**PHNOM PENH SEZ PLC.**
National Road No. 4, Sangkat Kantouk, Khan Posenchey, Phnom Penh, Cambodia
t +855 (0)23 729 798 f +855 (0)23 729 799 @ sales@ppsez.com
www.ppsez.com

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

នៅ ផ.ម.ក ។ គាត់ក៏ជាសមាជិកនៃអង្គភាពគណនេយ្យអន្តរជាតិដែលមានភាពល្បីល្បាញ នៅប្រទេសអូស្ត្រាលី និងជាអ្នកជំនាញ CPA ដែលមានបទពិសោធន៍ជាច្រើននៅក្នុងវិស័យគណនេយ្យរបស់គាត់អស់រយៈពេលជាច្រើនឆ្នាំ ។

ក្រៅពីការកិច្ចវិជ្ជាជីវៈរបស់គាត់ក្នុងនាមជាដៃគូរបស់ក្រុមហ៊ុន CPA លោក ARTHUR បានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់វិជ្ជាជីវៈគណនេយ្យនៅកម្ពុជាជាមួយអ្នកពាក់ព័ន្ធផ្សេងៗក្នុងរយៈពេលកន្លងមកនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបពីសេចក្តីជូនដំណឹងខាងលើ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០២១

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី PHNOM PENH SEZ PLC. KINGDOM OF CAMBODIA

PHNOM PENH SEZ PLC.
National Road No. 4, Sangkat Kantouk, Khan Posenchey, Phnom Penh, Cambodia
+855 (0)23 729 798 +855 (0)23 729 799 sales@ppsez.com
www.ppsez.com